**អង្គការថែរអន្តរជាតិប្រចាំកម្ពុជា**

# ឯកសារណែនាំសំរាប់ការបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងទឹក




០៨ កក្កដា ២០១០

គំរោងអភិវឌ្ឍន៍ជនបទចំរុះ និង កាត់បន្ថយគ្រោះមហន្តរាយ

និង

គំរោងសមាហរណកម្មសកម្មភាព កម្ពុជា-អូស្ត្រាលី

មាតិការ


| មាតិការ | ទំព័រ |
|---|---|
| ១. គោលការណ៍ណែនាំសំរាប់អ្នកបណ្តុះបណ្តាល | |
| ២. ការចុះឈ្មោះ និង បើកវគ្គបណ្តុះបណ្តាល | |
| ៣. លទ្ធផលរំពឹងទុក និង គោលបំណង | |
| ៤. ការគ្រប់គ្រងប្រពន្ធ័ស្រោចស្រព្វនៅកម្ពុជា | |
| ៥. ហេដ្ឋារចនាសម្ពន្ធ័គ្រប់គ្រងទឹក | |
| ៦. ការថែទាំ និង ការជួសជុលហេដ្ឋារចនាសម្ពន្ធ័គ្រប់គ្រងទឹក | |
| ៧. តួនាទី និង ការទទួលខុសត្រូវរបស់ក្រុមអ្នកប្រើប្រាស់ទឹក | |

# គោលការណ៍ណែនាំសំរាប់អ្នកបណ្តុះបណ្តាល

មានការប្រឹងប្រែង និង ការចាប់ផ្តើមជាច្រើនដែលមិនបានសំរេច តាមបំណងដោយសារកង្វះការបណ្តុះបណ្តាល និង ជំនាញរបស់ភ្នាក់ងារអភិវឌ្ឍន៍។ នៅលើពិភពលោក មានអ្នកបណ្តុះបណ្តាលតិចតួចដែលមានជំនាញ និងសមត្ថភាព អាចរៀបចំ និង អនុវត្តសកម្មភាពបណ្តុះបណ្តាលសំរាប់អភិវឌ្ឍន៍ជំនាញ និង សមត្ថភាពអ្នកធ្វើការងារអភិវឌ្ឍន៍ ។ មានសកម្មភាពបណ្តុះបណ្តាលដែលមិនបាន រៀបចំល្អ ឬ ប្រើប្រាស់វិធីសាស្ត្របុរាណដែលបានធ្វើអោយវគ្គបណ្តុះ បណ្តាលមិនមានប្រសិទ្ធភាព សំរាប់អ្នកចូលរួម។ ជាលទ្ធផល គឺគ្រាន់តែបានបញ្ចប់ការបណ្តុះបណ្តាល ជំនួសអោយការធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាពការងារនៃអ្នកចូលរួមគំរោង និង បុគ្គលិកអង្គការ ។

គំរោងកម្មវិធីបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងសំរាប់គណៈកម្មការក្រុមអ្នកប្រើប្រាស់ទឹក ដែលជាអ្នកចូលរួមក្នុងការគ្រប់គ្រងទឹក ក្រោមគំរោងអភិវឌ្ឍន៍ជនបទចំរុះ និង កាត់បន្ថយគ្រោះ មហន្តរាយ និង គំរោងសមាហរណកម្មសកម្មភាព កម្ពុជា-អូស្ត្រាលី ។ វគ្គនេះត្រូវបានរៀបចំ ដើម្បីបណ្តុះបណ្តាល និង អភិវឌ្ឍន៍ចំណេះដឹង និងការយល់ដឹងលើការងារគ្រប់គ្រងទឹក ដូចជាធ្វើអោយប្រសើរឡើងនូវការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃប្រពន្ធ័ស្រោចស្រព ។

គំរោងកម្មវិធីបណ្តុះបណ្តាលនេះបានរៀបចំឡើង ដោយផ្អែកលើតំរូវការ ដែលបានកំណត់ដោយបុគ្គលិកអង្គការឃែរ និង បុគ្គលិកមន្ទីរធនធានទឹក និង ឧត្តុនិយម តាមរយៈការអនុវត្តសកម្មភាពគំរោងនិងការប្រតិបត្តិការប្រចាំថ្ងៃជាមួយភ្នាក់ងារពាក់ពន្ធ័ ។ មាតិកានៃកម្មវិធីត្រូវបានរៀបចំដោយផ្អែកលើការវិភាគលើចំណុចខ្វះចន្លោះរបស់អ្នកចូលរួមគំរោង ។ ដូចនេះក្នុងការរៀបចំគំរោងកម្មវិធីបណ្តុះបណ្តាល វិធីសាស្ត្រ និង លំដាប់លំដោយនៃមាតិកាពីមួយទៅមួយមិនអាចរក្សាបានពេញលេញទេ ។ លើសពីនេះទៀត ដោយអ្នកចូលរួមបានទទួលការបណ្តុះបណ្តាលលើផ្នែកសំខាន់ៗមួយចំនួនរួចហើយពាក់ពន្ធ័និងវិធីសាស្ត្រ និង គោលគំនិត ។ ដូច្នេះចំណុចដែលផ្តោតក្នុងកម្មវិធីបណ្តុះបណ្តាលនេះ គឺជាផ្នែកសំខាន់ចាំបាច់ដែល **ត្រូវតែរៀន** និង មានពតិមានតិចតួចប៉ុណ្ណោះដែល **ជាការល្អក្នុងការរៀន** ។ នៅក្នុងគំរោងកម្មវិធី នេះបានព្យាយាមផ្តល់អោយអ្នកចូលរួមនូវគោលគំនិតជាទ្រឹស្តីតិចតួច ប៉ុន្តែផ្តោតច្រើនបំផុតទៅលើការអនុវត្តជាក់ស្តែងលើការរៀបចំផែនការ ការចាត់ចែង និង ការអនុវត្តការងារប្រពន្ធ័ស្រោចស្រពនៅកំរិតថ្នាក់ភូមិរបស់ពួកគេ ។ គំរោងកម្មវិធីនេះមិនបានព្យាយាមបង្រៀនអ្វីៗទាំងអស់ដល់គណៈកម្មការក្រុមអ្នកប្រើប្រាស់ទឹកគួរដឹងនោះទេ ប៉ុន្តែវគ្គបណ្តុះបណ្តាលនិងធ្វើអោយអ្នកចូលរួមដឹង និង ជួយពួកគេដើម្បីកំណត់នូវតំរូវការនៃបញ្ហាដែលជាប់ពាក់ពន្ធ័ទៅនិងការគ្រប់គ្រងទឹក ។ ដូចនេះ ពួកគេអាចស្វែងរកពីប្រភពផ្សេងៗទៀត ដើម្បីបង្កើនចំណេះ និង ការយល់ដឹងលើការការងារគ្រប់គ្រងទឹកនេះ ។